**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤ ពណ៌

## សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងឱកាសទិវាប្រជាជនពិភពលោកលើកទី៣២ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១

*សូមក្រាបថ្វាយបង្គំ សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ !*

*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី !*

*ជនរួមជាតិជាទីស្រឡាញ់រាប់អាន !*

ថ្ងៃនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ មានសេចក្តីសោមនស្សរីករាយ សូមគោរពទូលថ្វាយ និងថ្លែងទៅកាន់សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ថា ប្រជាជនកម្ពុជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយនឹងប្រជាជាតិនានាទូទាំងពិភពលោកប្រារព្ធ "**ទិវាប្រជាជនពិភពលោកលើកទី៣២**"។ អង្គការសហប្រជាជាតិតែងតែលើកទឹកចិត្តដល់បណ្តាភាគីទាំងអស់ឱ្យប្រារព្ធទិវាប្រជាជនពិភពលោកជារៀងរាល់ឆ្នាំនៅថ្ងៃទី១១ ខែកក្កដា ដោយផ្តោតលើប្រធានបទផ្សេងៗគ្នា។ ប្រធានបទឆ្នាំ២០២១នេះ គឺ "**សិទ្ធិនិងជម្រើស គឺជាចម្លើយ: មិនថាក្នុងដំណាក់កាលបន្ទុះ ឬសម្រុតនៃអត្រាកំណើតនោះទេ ដំណោះស្រាយ គឺស្ថិតនៅលើការផ្តល់អាទិភាពដល់សិទ្ធិនិងសុខភាពបន្តពូជសម្រាប់មនុស្សគ្រប់រូប (Right and Choice are the Anwser: Whether baby boom or bust, the solution lines in prioritizing the reproductive health and rights of all people)**"។ ប្រធានបទនេះ ពិតជាមានអត្ថន័យធំធេងក្នុងស្ថានភាព ដែលពិភពលោកទាំងមូលកំពុងប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ (កូវីដ-១៩) ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវិតមនុស្ស សហគមន៍ សេដ្ឋកិច្ចសង្គម និងសុខភាពសាធារណៈនៅគ្រប់ទិសទីទូទាំងពិភពលោក។ ស្ត្រីនិងក្មេងស្រី គឺជាក្រុមជនដែលងាយរងគ្រោះជាងគេដោយសារជំងឺរាតត្បាតកូវីដ-១៩ ជាពិសេស លើបញ្ហាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ។

តាមការវាយតម្លៃរបស់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ជំងឺរាតត្បាតកូវីដ-១៩ ដែលកំពុងបន្តអូសបន្លាយ បានធ្វើឱ្យប្រព័ន្ធថែទាំសុខភាពទូទាំងពិភពលោកចុះខ្សោយយ៉ាងខ្លាំង ហើយបង្កឱ្យមានចន្លោះប្រហោង និងបញ្ហាប្រឈមនានា ក្នុងការផ្តល់ព័ត៌មាន និងសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវ

ភេទក្នុងទំហំមួយយ៉ាងធំធេង។ លើសពីនេះទៀត ការបង្វែរធនធានចេញពីសេវាទាំងអស់នេះ កំពុងតែប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពស្ត្រីនិងក្មេងស្រី។ ស្ត្រីនិងក្មេងស្រី ដែលជាទូទៅមានចំណូលតិចតួចពីការងារដែលមិនសូវស្ថិតស្ថេរ កំពុងជួបនឹងផលវិបាកផ្នែកសេដ្ឋកិច្ចដែលបង្កដោយជំងឺកូវីដ-១៩ ហើយកំពុងប្រឈមនឹងហានិភ័យខ្ពស់ក្នុងបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ ដែលពួកគេងាយនឹងធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ លើសពីនេះទៀត ស្ត្រីមានការប្រឈមនឹងការកើនឡើងនូវបន្ទុកការងារដែលគ្មានប្រាក់ឈ្នួល ដែលរុញច្រានស្ត្រីជាច្រើននាក់ឱ្យចាកចេញពីកម្លាំងពលកម្មដែលមានប្រាក់ឈ្នួល។

ជាមួយគ្នានេះដែរ យោងតាមការវិភាគដំបូងរបស់ UNFPA លើទិន្នន័យដែលមានស្រាប់ ដែលភាគច្រើនបានមកពីបណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ បានបង្ហាញថា ជំងឺកូវីដ-១៩ អាចពន្លឿនការធ្លាក់ចុះលទ្ធភាពមានកូននៅក្នុងប្រទេសមួយចំនួន រួមទាំងនៅក្នុងបណ្តាប្រទេសអឺរ៉ុប និងសហរដ្ឋអាមេរិក នៅពេលគូស្វាមីភរិយាឆ្លើយតបទៅនឹងវិបត្តិដោយពន្យារពេលការមានផ្ទៃពោះ ឬផ្លាស់ប្តូរផែនការយកកូន។ ផ្ទុយទៅវិញ ទិន្នន័យនិងការធ្វើចំណោលក៏បានបង្ហាញថា នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបនិងមធ្យមមួយចំនួន, ជំងឺរាតត្បាតកូវីដ-១៩ បានរំខានដល់ការទទួលបានសេវាផែនការគ្រួសារ រួមទាំងការកើនឡើងការមានផ្ទៃពោះដោយចៃដន្យក្នុងចំណោមក្រុមងាយរងគ្រោះ។ ជាក់ស្តែង ការកើនឡើងនៃការមានផ្ទៃពោះដោយចៃដន្យ ត្រូវបានគេរកឃើញមានក្នុងចំណោមក្មេងជំទង់នៅប្រទេសកេនយ៉ា និងប្រទេសម៉ាឡាវី។

ការវាយតម្លៃដែលបានធ្វើការសន្និដ្ឋានថា ក្នុងស្ថានភាពនេះ ប្រជាជនជាច្រើនសម្តែងការព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះបម្រែបម្រួលអត្រាលទ្ធភាពមានកូន ដែលនៅកន្លែងខ្លះហាក់ដូចជាកំពុងតែកើនឡើងដោយសារតែការរាតត្បាតនៃជំងឺកូវីដ-១៩។ ជាប្រវត្តិសាស្ត្រ ទស្សនៈដែលខ្វល់ខ្វាយពីការមានកូនតិច បានបង្វិលការទទួលខុសត្រូវទៅលើស្ត្រីទាំងស្រុង ដោយមិនគិតពីបញ្ហាប្រឈមផ្នែកសង្គមនិងសេដ្ឋកិច្ចទូលំទូលាយដែលបង្កការលំបាកដល់ប្រជាជនក្នុងការកំណត់ចំនួនកូនតាមការចង់បាន។ ក្នុងករណីខ្លះ ទស្សនៈនេះបានឈានទៅដល់ការប្រើប្រាស់វិធីសាស្ត្រហួសសម័យ ដូចជា ការកាត់បន្ថយការទទួលបានសេវារំលូតកូនស្របច្បាប់ និង/ឬ ការរឹតត្បិតលើការពន្យាកំណើត។ នៅទីកន្លែងដែលមានប្រជាជនកើនឡើង ដើម្បីកាត់បន្ថយអត្រាលទ្ធភាពមានកូន ការដាក់ចេញនូវការធ្វើផែនការគ្រួសារបង្ខំនិងការក្រៀវរួមបញ្ចូលគ្នា គឺជាការឆ្លើយតបផ្នែកគោលនយោបាយមួយប្រកបដោយគ្រោះថ្នាក់។

ការខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ទទួលបានជោគជ័យពេញមួយឆ្នាំ២០២០ ដែលមានអ្នកឆ្លងក្នុងរង្វង់ត្រឹមតែ ៣៥០ ករណីប៉ុណ្ណោះ និងមិនមានអ្នកស្លាប់សូម្បីតែម្នាក់។ ប៉ុន្តែ ជាអកុសលឆ្នាំ២០២១នេះ ករណីឆ្លងជំងឺកូវីដ-១៩ មានការកើនឡើងយ៉ាងគំហុក ដែលបានធ្វើឱ្យរាជរដ្ឋាភិបាល ក៏ដូចជាប្រជាជនកម្ពុជាទាំងមូលមានការព្រួយបារម្ភយ៉ាងខ្លាំង។ ជាក់ស្តែង គិតត្រឹមថ្ងៃទី២៦ ខែមិថុនានេះ មានអ្នកឆ្លងជំងឺកូវីដ-១៩ ចំនួន ៤៨ ៥៣២ករណី, ស្លាប់ ៥៥៦នាក់ និងអ្នកជាសះស្បើយ ៤២ ៧៦៤នាក់។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាល អាចគ្រប់គ្រងស្ថានការណ៍នេះបានល្អ និងកំពុងបន្តយុទ្ធនាការចាក់វ៉ាក់សាំងទ្រង់ទ្រាយធំទូទាំងប្រទេស។ គិតត្រឹមថ្ងៃទី២៣ ខែមិថុនានេះ ការចាក់វ៉ាក់សាំងដូសទី១នៅទូទាំងប្រទេស សរុបបានចំនួនជាង ៣,៦លាននាក់ ស្មើនឹងប្រមាណ ៣៦% នៃប្រជាជនគោលដៅចំនួន ១០លាននាក់ ក្នុងនោះអ្នកដែលបានចាក់វ៉ាក់សាំងដូសទី២ សរុបជាង ២,៧លាននាក់។

នៅក្នុងវិស័យសុខភាពសាធារណៈ ជាពិសេសសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ រាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់និងផ្តល់អាទិភាពខ្ពស់តាំងពីមុនការផ្ទុះឡើងនៃជំងឺកូវីដ-១៩មកម្លេះ។ ជាក់ស្តែងការដាក់ចេញនូវយុទ្ធសាស្ត្រជាតិស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ២០១៧-២០២០ គឺសំដៅផ្តល់អាទិភាពដល់វិស័យសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ដោយធានាថា ប្រជាជនទាំងអស់នៅក្នុងប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍កាន់តែច្រើនពីយុទ្ធសាស្ត្រនេះ ជាពិសេស សិទ្ធិអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់ស្ត្រីនិងក្មេងស្រី។ យុទ្ធសាស្ត្រជាតិស្តីពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ បន្តផ្តោតការយកចិត្តទុកដាក់លើការបង្កើនការគ្របដណ្តប់ គុណភាព និងការប្រើប្រាស់កិច្ចអន្តរាគមន៍ ដែលបង្ហាញពីប្រសិទ្ធភាពក្នុងការលើកកម្ពស់សុខភាពនិងសិទ្ធិបន្តពូជនិងផ្លូវភេទ ក្នុងការកាត់បន្ថយការស្លាប់របស់ម្តាយ។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ បាននិងកំពុងខិតខំប្រឹងប្រែងពង្រឹងនិងពង្រីកកិច្ចអន្តរាគមន៍លើផ្នែកសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការលើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវានៅក្នុងតំបន់ដែលកំពុងជួបប្រទះកង្វះខាត ដូចជា តំបន់ភាគខាងជើងនិងឦសាននៃប្រទេស ក៏ដូចជានៅក្នុងចំណោមក្រុមងាយរងគ្រោះនានា ដូចជា យុវវ័យ ក្រុមជនជាតិដើមភាគតិច កម្មករចំណាកស្រុក (រួមទាំងកម្មករកាត់ដេរ កម្មករសំណង់ អ្នកធ្វើការក្នុងសេវាកំសាន្ត និងកម្មករកសិកម្ម) និងជនពិការ។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់!

ឆ្លើយតបទៅនឹងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាល បានបន្តជំរុញអនុវត្តគោលនយោបាយគាំពារសង្គម និងបានដាក់ចេញវិធានការអន្តរាគមន៍ជំនួយសង្គមបន្ថែមទៀត សំដៅជួយសម្រាលការលំបាក និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដែលមានជីវភាពក្រីក្រ ជាពិសេសស្ត្រីនិងក្មេងស្រី។ រាជរដ្ឋាភិបាល នៅតែបន្តអនុវត្តកម្មវិធីឧបត្ថម្ភចំពោះកម្មការិនីដែលជាស្ត្រីមានផ្ទៃពោះនិងគ្រួសារដែលមានជីវភាពក្រីក្រ ការបង្កើនមូលធនថវិកា "សាច់ប្រាក់ពលកម្ម" ដើម្បីជួយដល់កម្មករនិយោជិតដែលបានព្យួរការងារអំឡុងពេលដែលរោងចក្រសហគ្រាស គ្រឹះស្ថាន ក្នុងវិស័យកាត់ដេរ និងទេសចរណ៍មួយចំនួនបានផ្អាកដំណើរការ និងកម្មវិធីជំនួយសង្គមថ្មីមួយទៀត ដែលជាកម្មវិធីជំនួយសង្គមពិសេស គឺ "**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩**" ដែលត្រូវបានប្រកាសឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០កន្លងទៅនេះ សំដៅជួយដល់ប្រជាជនដែលមានជីវភាពក្រីក្រនិងងាយរងគ្រោះដែលមានប័ណ្ណសមធម៌ (ក្រ-១ និង ក្រ-២)។

ថ្មីៗនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសេចក្តីសម្រេចស្តីពីយន្តការនិងនីតិវិធីនៃការអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ សម្រាប់ប្រជាពលរដ្ឋនិងគ្រួសារប្រជាពលរដ្ឋមានការលំបាកផ្នែកជីវភាព រួមមាន ប្រជាពលរដ្ឋនិងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ។ រាជរដ្ឋាភិបាល នឹងពិនិត្យលទ្ធភាពគ្របដណ្តប់ ១០០% ចំពោះអ្នកមានប័ណ្ណក្រីក្រ តាមរយៈមូលនិធិសមធម៌សុខភាព និងគ្របដណ្តប់លើកម្មករផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធ/មន្ត្រីរាជការស៊ីវិល តាមរយៈគម្រោងរ៉ាប់រងធានាសុខភាពមន្ត្រីរាជការស៊ីវិលនៃ ប.ស.ស. ដែលមានកញ្ចប់អត្ថប្រយោជន៍/ប្រព័ន្ធបង់ប្រាក់ ដែលគ្រប

ដំណាក់កាលបញ្ចប់ការលើកកម្ពស់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទពេញលេញលើគ្រប់កម្រិតថ្នាក់ នៃការថែទាំដែលមានការផ្តល់សេវា។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ!

ទោះក្នុងកាលៈទេសៈណាក៏ដោយ រាជរដ្ឋាភិបាល នៅតែផ្តល់អាទិភាពខ្ពស់លើវិស័យសុខភាពសាធារណៈ តាមរយៈការបង្កើនកិច្ចអន្តរាគមន៍ និងការបង្កើនថវិកាជាតិរៀងរាល់ឆ្នាំ ជាពិសេសលើវិស័យសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សំដៅពង្រឹងការលើកកម្ពស់សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ដែលជាមធ្យោបាយមួយនៃការឈានទៅសម្រេចបានគោលដៅការកាត់បន្ថយអត្រាមរណភាពមាតានិងទារក ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ខ្ញុំព្រះករុណា ខ្ញុំ សូមឆ្លៀតយកឱកាសដ៏មានតម្លៃនេះ សូមថ្លែងអំណរគុណដល់ជនរួមជាតិទាំងអស់ ជាពិសេសមន្ត្រីសុខាភិបាលជួរមុខ កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ដែលបានចូលរួមគាំទ្រនិងរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងសូមជនរួមជាតិទាំងអស់បន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣កុំ និង ៣ការពារ ដើម្បីរួមចំណែកក្នុងការបញ្ឈប់ការរីករាលដាលជំងឺកូវីដ-១៩ ទាំងស្រុងនៅក្នុងប្រទេសកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះអង្គការសហប្រជាជាតិ ជាពិសេសអង្គការសុខភាពពិភពលោក និងបណ្តាប្រទេសជាមិត្តទាំងអស់ដែលបានគាំទ្រដល់កម្ពុជា ទាំងស្មារតី ទាំងសម្ភារៈសុខាភិបាលនិងវិធីសាស្ត្រព្យាបាលនិងទប់ស្កាត់ការឆ្លងកូវីដ-១៩ នៅក្នុងស្ថានភាពដ៏លំបាកនេះ ជាពិសេស សាធារណរដ្ឋប្រជាមានិតចិន ប្រទេសជប៉ុន និងសហរដ្ឋអាមេរិក។

ជាទីបញ្ចប់នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរដល់សម្តេចអគ្គមហាសង្ឃរាជ សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**